ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤១៧ សណណន. កសក

# សារាចរណែនាំ
## ស្តីពី
## វិធានការទប់ស្កាត់និងបង្ក្រាបបទល្មើសជលផលដោយប្រើឧបករណ៍នេសាទលប ណ ឬរ៉ាវ "ប" ការប្រើឧបករណ៍សាច់អួនឬមងរួមផ្សំភ្លើងធ្វើឱ្យត្រីកុំ( ឈ្នក់ )អួនអូសទឹកសាប និងការធ្វើនេសាទដោយឧបករណ៍ឈិបយន្ត

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានកត់សម្គាល់ឃើញថា ការទប់ស្កាត់និងបង្ក្រាបបទល្មើសជលផលដោយប្រើឧបករណ៍នេសាទលបណឬរ៉ាវ (ប) ការនេសាទដោយឧបករណ៍សាច់អួនឬមងរួមផ្សំភ្លើងធ្វើឲ្យត្រីកុំ(ឈ្នក់) ការធ្វើនេសាទដោយឧបករណ៍អួនអូសទឹកសាប និងការធ្វើនេសាទដោយឧបករណ៍នេសាទឈិបយន្តកំពុងមានសកម្មភាពគួរឲ្យព្រួយបារម្ភដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់និរន្តរភាពធនធានជលផលនិងប្រភេទជីវចម្រុះផ្សេងៗទៀតនៅក្នុងតំបន់បឹងទន្លេសាបនិងតំបន់ដទៃទៀត។

ឧបករណ៍លប ណ ឬរ៉ាវកន្លងមក ជាឧបករណ៍នេសាទសិប្បកម្មដែលអនុញ្ញាតឲ្យធ្វើនេសាទ ប៉ុន្តែក្រោយឆ្នាំ២០១២ បន្ទាប់ពីរាជរដ្ឋាភិបាលបានសម្រេចលុបឡូត៍នេសាទទាំងស្រុងមក ឧបករណ៍នេសាទប្រភេទនេះត្រូវបានហាមឃាត់មិនអនុញ្ញាតឲ្យធ្វើនេសាទដោយហេតុថា ទំហំរបស់វាធំ រីឯការប្រើដើមទុនក៏ច្រើនហើយប៉ះពាល់ដល់កន្លែងនេសាទគ្រួសារឬសហគមន៍នេសាទ និងប្រសិទ្ធភាពចាប់ត្រីខ្ពស់ជាងបណ្តាឧបករណ៍នេសាទដទៃទៀត និយាយរួមឧបករណ៍នេសាទនេះមានទំហំនិងទ្រង់ទ្រាយប្រហាក់ប្រហែលផ្នែកមួយនៃឡូត៍នេសាទផងដែរ។ បច្ចុប្បន្ន ប្រភេទឧបករណ៍នេសាទនេះ ត្រូវបានកែច្នៃខុសទម្រង់ដើមស្ទើរតែទាំងស្រុង គឺការប្រើរបាំងសាច់អួនឬមងក្រឡាញឹកជំនួសរបាំងព្រួល(ឬស្សី) ការប្រើលូសាច់អួនក្រឡាញឹកឬស្បៃមុងជំនួសឡុកធ្វើជាកន្លែងប្រមូលផលត្រី និងការកាប់រានព្រៃលិចទឹកដើម្បីធ្វើគន្លងនេសាទជាដើម។ល។ ឧបករណ៍នេសាទលប ណ ឬរ៉ាវកែច្នៃបច្ចុប្បន្ននេះ មានឈ្មោះថ្មីក្រៅផ្លូវការថា ឧបករណ៍នេសាទ"ប"។ រីឯការធ្វើនេសាទឧបករណ៍សាច់អួនឬមងរួមផ្សំភ្លើងឬនុយត្រងចាប់ត្រី "ឈ្នក់" វិញ គឺជាឧបករណ៍ផលិតបែបថ្មី ប្រើដើមទុនតិច ងាយស្រួលផលិត និងមានប្រសិទ្ធភាពចាប់ត្រីខ្ពស់។ ឧបករណ៍នេសាទនេះ នៅទន្លេសាបមានឈ្មោះក្រៅផ្លូវការថា"ឈ្នក់" ប៉ុន្តែពុំមែនជាឧបករណ៍នេសាទឈ្នក់ដូចទម្រង់ដើមដែលអនុញ្ញាតឲ្យនេសាទនៅតំបន់ទន្លេមេគង្គទេ។ ចំណែកឧបករណ៍នេសាទអួនអូសទឹកសាបនិងឈិបយន្តវិញគឺជាឧបករណ៍នេសាទហាមឃាត់ដែលមិនអនុញ្ញាតឱ្យធ្វើនេសាទនៅទឹកសាបឡើយ។

ដូចនេះ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសធ្វើនេសាទដោយឧបករណ៍ខាងលើឲ្យទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាពនិងត្រឹមត្រូវស្របតាមច្បាប់ស្តីពីជលផលនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់សមត្ថកិច្ចរដ្ឋបាលជលផលគ្រប់ថ្នាក់ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធនិងអាជ្ញាធរដែនដីចាត់វិធានការឲ្យបានម៉ឺងម៉ាត់និងតឹងរ៉ឹងបំផុតដូចខាងក្រោម៖

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣)៧២៦ ១២៨ /៧២៦ ១២៩ ទូរសារលេខ: (៨៥៥)២៣-២១៧ ៣២០
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

**១-ឧបករណ៍នេសាទ ប**

សមត្ថកិច្ចរដ្ឋបាលជលផលគ្រប់ថ្នាក់ត្រូវសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិនិងសមត្ថកិច្ចពាក់ព័ន្ធជាពិសេស គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដោយចាត់វិធានការទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល"ប" ឱ្យបានម៉ឺងម៉ាត់។ ក្នុងករណីជួបប្រទះជនប្រព្រឹត្តបទល្មើសនៅនឹងកន្លែងព្រមទាំងវត្ថុតាងបទល្មើសជលផលនោះ មន្ត្រីនគរបាលយុត្តិធម៌ជលផលត្រូវរៀបចំសំណុំរឿងតាមនីតិវិធីដូចមានចែងក្នុងប្រកាសរួមលេខ១១៥ កយ.កសក.ប្រក/១១ និងលេខ៥៧០កសក.ប្រក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពី"ទម្រង់បែបបទនៃកំណត់ហេតុបទល្មើសជលផល" របស់ក្រសួងយុត្តិធម៌និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាបន្ទាន់ដោយចោទប្រកាន់ល្មើសនឹងមាត្រា២០និងត្រូវផ្តន្ទាទោសតាមមាត្រា៩៨ នៃច្បាប់ស្តីពីជលផល។ ក្នុងករណីជនប្រព្រឹត្តបទល្មើសរត់គេចខ្លួន នោះត្រូវស្រាវជ្រាវរកអត្តសញ្ញាណជនល្មើសហើយរៀបចំចងក្រងសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ចដូចករណីមានវត្ថុមានជនល្មើសនៅនឹងកន្លែងបទល្មើសជលផលកើតឡើងឬកន្លែងកើតហេតុដែរ ប៉ុន្តែការស្រាវជ្រាវនេះ មិនត្រូវលើសរយៈពេល៧ ថ្ងៃទេ។

**២-ឧបករណ៍នេសាទឈ្នក់**

ចំពោះឧបករណ៍នេសាទដោយប្រើសាច់អួនឬមងរួមផ្សំភ្លើងឬទុយ៉ត្រងចាប់ត្រីឈ្នក់ រដ្ឋបាលជលផលមានសមត្ថកិច្ចគ្រប់ថ្នាក់នៅពេលចេញប្រតិបត្តិការត្រួតពិនិត្យបទល្មើសជលផល ហើយជួបប្រទះជនប្រព្រឹត្តបទល្មើសនៅនឹងកន្លែងឬជនល្មើសរត់គេចខ្លួនបាត់នោះ មន្ត្រីនគរបាលយុត្តិធម៌ជលផលត្រូវធ្វើកំណត់ហេតុនិងកសាងសំណុំរឿងចោទប្រកាន់ទៅតុលាការមានសមត្ថកិច្ចដូចករណីចោទប្រកាន់បទល្មើសជលផលឧបករណ៍នេសាទ "ប" ដែរ។

**៣-ឧបករណ៍នេសាទអួនអូសទឹកសាបឬឈិបយន្ត**

ការចេញប្រតិបត្តិការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល ហើយជួបប្រទះជនល្មើសប្រើប្រាស់ឧបករណ៍និងវត្ថុតាងបទល្មើសឬជនល្មើសរត់គេចខ្លួនបាត់នោះ មន្ត្រីនគរបាលយុត្តិធម៌ជលផលត្រូវចាត់វិធានការដូចខាងក្រោម៖

**ក-វិធានការទប់ស្កាត់**

ករណីជួបប្រទះការផលិត ការទិញ ការលក់ ការដឹកជញ្ជូនផលផលិតផលជលផល និងការថែរក្សាឧបករណ៍ នេសាទអួនអូសទឹកសាប និងឈិបយន្ត មន្ត្រីនគរបាលយុត្តិធម៌ជលផលមានសមត្ថកិច្ចគ្រប់ថ្នាក់ត្រូវចាត់វិធានការអនុវត្តដូចចំណុច១ ខាងលើដែរ ប៉ុន្តែការកសាងសំណុំរឿងបទល្មើសជលផលត្រូវចោទប្រកាន់ល្មើសនឹងមាត្រា២១ ដែលត្រូវផ្តន្ទាទោសតាមមាត្រា១០១ នៃច្បាប់ស្តីពីជលផល។

**ខ-វិធានការបង្ក្រាបបទល្មើសដំណាក់កាលប្រព្រឹត្ត**

មន្ត្រីនគរបាលយុត្តិធម៌ជលផលគ្រប់ថ្នាក់ក្នុងពេលចេញប្រតិបត្តិការ ហើយបានជួបប្រទះជនល្មើសនិងវត្ថុតាងបទល្មើសជលផលអួនអូសឬឈិបយន្តដែលកំពុងធ្វើនេសាទនៅក្នុងដែននេសាទទឹកសាប ឬករណីជនល្មើសរត់គេចខ្លួនបាត់ ត្រូវធ្វើកំណត់ហេតុឬស្រាវជ្រាវសាវតារជាតិជនល្មើសរួចកសាងសំណុំរឿងបទល្មើសជលផលបញ្ជូនទៅតុលាការមានសមត្ថកិច្ច ដោយចោទប្រកាន់ល្មើសនឹងមាត្រា២០ ដែលត្រូវផ្តន្ទាទោសតាមមាត្រា៩៩ នៃច្បាប់ស្តីពីជលផល។

ក្រោយពីទទួលបានសារាចរណែនាំនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថា រដ្ឋបាលជលផលនិងមន្ត្រីនគរបាលយុត្តិធម៌ជលផលទាំងអស់ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តជូនក្រសួងវិញ៕

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- សាលារាជធានី ខេត្ត "ដើម្បីជូនជ្រាប"
- អគ្គាធិការដ្ឋាន
- រដ្ឋបាលជលផល "ដើម្បីសហការនិងអនុវត្ត"
- ឯកសារ កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វ៉េង សាខុន**